# សេចក្តីពន្យល់អំពីអង្គហេតុចំបងដែលជាធាតុផ្សំ

~ករណីស្តីពីការទាមទារឱ្យចុះបញ្ជីលុបនូវការចុះបញ្ជី~

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
សាស្ត្រាចារ្យ Mr. Uchiyama Jun

1

# រឿងក្តីស្តីពីការចុះបញ្ជីលុបនូវការចុះបញ្ជី

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ

2

# 1. សាលក្រមដែលទាមទារ

“ចំពោះដីដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធ ចុងចម្លើយត្រូវធ្វើនីតិវិធីចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធស្ដីពីការចុះបញ្ជី”

3

# 1. សាលក្រមដែលទាមទារ

ប្រភេទបណ្ដឹងទាមទារឱ្យបង្ហាញឆន្ទៈថា ដាក់ពាក្យសុំចុះបញ្ជី

- ជាគោលការណ៍ ការដាក់ពាក្យសុំចុះបញ្ជី គឺត្រូវធ្វើឡើងរួមគ្នា

  (ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការទី១០ កថាខ័ណ្ឌទី១)

→គេចាត់ទុកថា ភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដាក់ពាក្យសុំចុះបញ្ជី តាមរយៈសាលក្រមដែលទទួលស្គាល់នូវការទាមទារដូច្នេះ អាចដាក់ពាក្យសុំតែឯងបាន(ប្រការដដែល កថាខ័ណ្ឌទី២)

→ត្រូវសរសេរអំពីចំណុចស្របទៅនឹងការដាក់ពាក្យសុំ

(សូមមើលប្រកាសអន្តរក្រសួងដដែលពីប្រការទី២៨ទៅ)

Ex: ចំណុចពិសេសពាក់ព័ន្ធនឹងអចលនវត្ថុដែលជាកម្មវត្ថុ, មូលហេតុនៃការចុះបញ្ជី

4

# 1. សាលក្រមដែលទាមទារ

<u>ប្រភេទបណ្ដឹងទាមទារឱ្យបង្ហាញឆន្ទៈថា ដាក់ពាក្យសុំចុះបញ្ជី</u>

・មិនមែនចុងចម្លើយជាអ្នកចុះបញ្ជីទេ គឺមន្ត្រីចុះបញ្ជីជាអ្នកធ្វើ។

× "ត្រូវចុះបញ្ជី"

○ "ត្រូវធ្វើនីតិវិធីចុះបញ្ជី"

・មិនភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នទេ។

→ ពេលសាលក្រមចូលជាស្ថាពរ គេចាត់ទុកថា បានបង្ហាញឆន្ទៈ

(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា529)

5

# 1. សាលក្រមដែលទាមទារ

<u>ប្រភេទបណ្ដឹងទាមទារឱ្យបង្ហាញឆន្ទៈថា ដាក់ពាក្យសុំចុះបញ្ជី</u>

※កិច្ចការជាក់ស្ដែងនៅជប៉ុន

・ចំណុចពិសេសពាក់ព័ន្ធនឹងអចលនវត្ថុ ឬ ការចុះបញ្ជី គេច្រើនសរសេរលំអិតនៅក្នុង "ឯកសារឧបសម្ព័ន្ធ" (ពន្យល់នៅខាងក្រោយ)

・នៅក្នុងបណ្ដឹងស្ដីពីការចុះបញ្ជីលុបចោលនូវការចុះបញ្ជី គេអាចមិនសរសេរដូចខាងក្រោមនេះទេ

△ "ចំពោះដើមចោទ"

△ មូលហេតុនៃការចុះបញ្ជី

6

## ឧទាហរណ៍នៃបញ្ជីសារពើភ័ណ្ឌនៃអចលនវត្ថុ

※ធ្វើតាមកូឡោន “អត្តសញ្ញាណនៃអចលនវត្ថុ” នៃសៀវភៅគោលបញ្ជីដីធ្លី

**បញ្ជីសារពើភ័ណ្ឌនៃអចលនវត្ថុ**

ទីតាំង 1, Fukushima , Fukushima-ku, Osaka-shi
លេខឡូ 1-60
ប្រភេទដី ដីលំនៅដ្ឋាន
ផ្ទៃដី 123.45㎡

7

## ឧទាហរណ៍នៃបញ្ជីសារពើភ័ណ្ឌស្តីពីការចុះបញ្ជី

※ ធ្វើតាមកូឡោន “ចំណុចស្តីពីកម្មសិទ្ធិ” នៃសៀវភៅគោលបញ្ជីដីធ្លី។

**បញ្ជីសារពើភ័ណ្ឌស្តីពីការចុះបញ្ជី**

មន្ទីរនីត្យានុកូលកម្មអូសាកា ទទួលនៅថ្ងៃទី៣ កុម្ភ ២០១៥
ផ្ទេរកម្មសិទ្ធិ លេខ១០០
មូលហេតុ លក់ទិញនៅថ្ងៃទី១០ មករា ២០១៥
កម្មសិទ្ធិករ ហ្វូមីអ៊ីជីរ៉ូ
អាស័យដ្ឋាន ៖ 1-1-1 Kasumigaseki, Chiyoda-ku, Tokyo

8

## រឿងក្ដីស្ដីពីការចុះបញ្ជីលុបនូវការចុះបញ្ជី

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ



## 2. ការទាមទារ

សិទ្ធិទាមទារនូវការចុះបញ្ជីលុបចោលនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ក្នុងនាមជាសិទ្ធិទាមទារឱ្យបំបាត់ការរាំង ដោយផ្អែកលើកម្មសិទ្ធិ

## រឿងក្ដីស្ដីពីការចុះបញ្ជីលុបនូវការចុះបញ្ជី

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ

11

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

<u>សិទ្ធិទាមទារនូវការចុះបញ្ជីលុបចោលនូវការចុះបញ្ជី ក្នុងនាមជាសិទ្ធិទាមទារឱ្យបំបាត់ការរាំង ដោយផ្អែកលើកម្មសិទ្ធិ</u>

A) កម្មសិទ្ធិរបស់ដើមចោទ (មាត្រា159 កថាខ័ណ្ឌទី1 “កម្មសិទ្ធិករ”

- ប្រសិនជាមានការទទួលស្គាល់កម្មសិទ្ធិនាពេលណាមួយ សិទ្ធិនោះនឹងនៅតែមានអត្ថិភាពបន្ត បើសិនជាពុំមានសភាពការណ៍ណាមួយរារាំងទេ។

  →នៅក្នុងករណីនេះ ស្ដីពីកម្មសិទ្ធិរបស់ X នៅពេលដែល Xបានលក់ទៅឱ្យ Y Y ក៏ទទួលស្គាល់ដែរ (ការសារភាពអំពីសិទ្ធិ)។

B) ការចុះបញ្ជីឈ្មោះរបស់ចុងចម្លើយ (មាត្រា159 កថាខ័ណ្ឌទី1 “ការរារាំង”

12

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

A) "នាថ្ងៃទី០ មេសា ២០១៤ ដើមចោទមានកម្មសិទ្ធិទៅលើដី B (ដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធនៃអចលនវត្ថុ)"។

B) "ស្ដីពីដី B មានការចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឱ្យឈ្មោះចុងចម្លើយ (ដែលមាននៅក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធស្ដីពីការចុះបញ្ជី)"។



## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

↓ ប៉ុន្តែ ...

ស្ដីពីការចុះបញ្ជីអចលនវត្ថុ មាន "ការសន្មតតាមផ្លូវច្បាប់" ថា , អ្នកដែលមានឈ្មោះក្នុងបញ្ជី គឺជាអ្នកមានសិទ្ធិ (មាត្រា137 កថាខ័ណ្ឌទី1)

↓ ហេតុនេះហើយ

ប្រសិនបើដើមចោទអះអាងអំពីការចុះបញ្ជីរបស់ចុងចម្លើយ (ចំណុច B ខាងលើនេះ) ជាអង្គហេតុ "រារាំង" (មាត្រា159 កថាខ័ណ្ឌទី1) ជាលទ្ធផល ត្រូវសន្និដ្ឋានថា ចុងចម្លើយមានសិទ្ធិ (កម្មសិទ្ធិ) ( មាត្រា137 កថាខ័ណ្ឌទី1 )

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

↓ ហេតុនេះហើយ

ដើមចោទត្រូវធ្វើការបញ្ជាក់ភស្តុតាងថា ការចុះឈ្មោះរបស់ចុងចម្លើយនោះគ្មានសុពលភាពទេ(នៅក្នុងចំណុច C ខាងក្រោមនេះ)

C) ការចុះឈ្មោះរបស់ចុងចម្លើយនោះគ្មានសុពលភាព

15

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

↓ លំអិតគឺ

①ក្នុងរឿងក្ដីនេះ ជាក់ស្ដែង រវាងភាគី ពុំមានវិវាទស្ដីពីសុពលភាពនៃការបង្កើតកិច្ចសន្យាលក់ទិញទេ។

↓ ប៉ុន្តែ

②ដើមចោទអះអាងអំពីអសុពលភាពនៃការចុះបញ្ជី ដោយសារតែបានលុបចោលនូវកិច្ចសន្យាលក់ទិញ ដោយផ្អែកលើការភាន់ច្រឡំ។

16

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

↓ ម្យ៉ាងទៀត

ពេលអះអាងថា មានការភាន់ច្រឡំ

មានន័យថា បានអះអាងអំពីអង្គហេតុនៃ①ខាងលើនេះ (ក្នុងC-1 ខាងក្រោម )

↓ បន្ទាប់មក

អះអាងអំពីការភាន់ច្រឡំ ៖

អះអាងអំពីអង្គហេតុពាក់ព័ន្ធនឹង②ខាងលើនេះ ( ក្នុងC-2 ខាងក្រោម)



## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

<u>ការលក់ទិញ</u>

C) -1-1 ការបង្កើតកិច្ចសន្យាលក់ទិញ(មាត្រា515)

-1-2 ការធ្វើលិខិតយថាភូត

(មាត្រា336: ល័ក្ខខ័ណ្ឌដើម្បីឱ្យមានអានុភាព )

-1-3 ការចុះបញ្ជីឈ្មោះចុងចម្លើយដោយផ្អែកលើការលក់ទិញ

(មាត្រា135:ល័ក្ខខ័ណ្ឌដើម្បីឱ្យមានអានុភាព)

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

C) -1-1

“នៅថ្ងៃទី០ មេសា២០១៩ ដើមចោទបានលក់ដី B ទៅឱ្យចុងចម្លើយ ក្នុងតម្លៃ 3ម៉ឺនដុល្លារ”

-1-2

“ដើមចោទនិងចុងចម្លើយបានធ្វើលិខិតយថាភូតដែលមានខ្លឹមសារលក់ទិញនោះ”

-1-3

“ការចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រូវបានធ្វើឡើងដោយផ្អែកលើការលក់ទិញខាងលើនេះ”

19

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### <u>ការលុបចោលដោយសារការភាន់ច្រឡំ</u>

C) -2-1 ការភាន់ច្រឡំ(មាត្រា346 កថាខ័ណ្ឌទី2)

-2-2 ចំណុចដែលភាគីម្ខាងយល់ថាសំខាន់ ក្នុងការបង្កើតកិច្ចសន្យា

(កថាខ័ណ្ឌដដែល វាក្យខ័ណ្ឌទី២:ការភាន់ច្រឡំអំពីមូលហេតុនៃការបង្កើតកិច្ចសន្យា)

-2-3 អង្គហេតុដែលជាមូលដ្ឋាននៃការវាយតម្លៃថា ភាគីម្ខាងទៀតអាចដឹងអំពីចំណុច 2-1 និង2-2 ខាងលើនេះ

(កថាខ័ណ្ឌដដែល:អង្គហេតុចំបងដែលជាលក្ខណ:អរូបី)

-2-4 ការបង្ហាញឆន្ទ:លុបចោល

※មាត្រា346 កថាខ័ណ្ឌទី1 គឺជាបញ្ញត្តិចែងអំពីចំណុចសំខាន់ច្បាស់លាស់ ដូច្នេះ មិនត្រូវនឹងរឿងក្តីនេះទេ។

※ដោយពិចារណាដល់តុល្យភាពរវាងការការពារអ្នកបង្ហាញឆន្ទ: និង សុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការ អ្នកភាន់ច្រឡំត្រូវធ្វើការបញ្ជាក់ភស្តុតាងនៃអង្គហេតុ C)-2-3។

20

## ស្តីពីអង្គហេតុចំបងដែលជាលក្ខណៈអរូបី

កំហុស ជាអាទិ៍(អង្គហេតុចំបងដែលជាលក្ខណៈអរូបី)
→ទស្សនៈទូទៅនិងអរូបី នៃការវាយតម្លៃជាលក្ខណៈអរូបី

ដើម្បីធ្វើការវាយតម្លៃជាលក្ខណៈអរូបី ចាំបាច់ត្រូវមានអង្គហេតុច្បាស់លាស់ដែលជាមូលដ្ឋាននៃការវាយតម្លៃ (អង្គហេតុដែលវាយតម្លៃវិជ្ជមាន)
→ភាគច្រើន គេចាត់ទុកថា អង្គហេតុជាក់ស្តែងលំអិតបែបនេះ គឺជាអង្គហេតុចំបងដែលជាធាតុផ្សំ (នៅជប៉ុន)។

※សូមមើលស្លាយដ៍ស្តីពី "សេចក្តីពន្យល់អំពីអង្គហេតុចំបងដែលជាធាតុផ្សំ ~ករណីស្តីពីប្រាក់កម្ចី, ករណីស្តីពីអំពើអនីត្យានុកូល ~

21

## ស្តីពីអង្គហេតុចំបងដែលជាលក្ខណៈអរូបី

【អង្គហេតុដែលវាយតម្លៃវិជ្ជមាន】

អង្គហេតុដែលជាមូលដ្ឋានវិជ្ជមាន(+)ក្នុងការវាយតម្លៃជាលក្ខណៈអរូបី

【 អង្គហេតុដែលវាយតម្លៃអវិជ្ជមាន】

អង្គហេតុដែលជាមូលដ្ឋានអវិជ្ជមាន(-)ក្នុងការវាយតម្លៃជាលក្ខណៈអរូបី

→ គេច្រើនតែចាត់ទុកថា ជាអង្គហេតុតវ៉ា (ជប៉ុន)។

22

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

C) -2-1 ការភាន់ច្រឡំ

"ផែនការណ៍អភិវឌ្ឍន៍រមនីយដ្ឋាននៃដី B នៅតែមានដំណើរការទៅមុខ តែដើមចោទមានជំនឿថា ផែនការណ៍នេះត្រូវបានផ្អាក"



## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

C) -2-2 ចំណុចដែលភាគីគិតថា សំខាន់ក្នុងការបង្កើតកិច្ចសន្យា

"ដើមចោទបានឮថា ផែនការណ៍អភិវឌ្ឍរមនីយដ្ឋាននៃដី B ត្រូវបានផ្អាក ហើយគេបានរៀបចំផែនការណ៍សាងសង់រោងចក្រដុតសម្រាមទៅវិញ ដូច្នេះហើយ បើសិនជាគេប្រកាសផែនការណ៍សាងសង់រោងចក្រដុតសម្រាមទៅ ដីនោះច្បាស់ជានឹងចុះតម្លៃយ៉ាងខ្លាំង ហើយនឹងខាងធ្ងន់ ដើមចោទក៏បានបង្ហាញឆន្ទៈលក់ដីនោះទៅ "

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

C) -2-3 សភាពការណ៍សំខាន់ៗស្តីពីការបានដឹងអំពីការភាន់ច្រឡំ

“ពេលចរចារអំពីកិច្ចសន្យាជាមួយនឹងចុងចម្លើយ ដើមចោទបាននិយាយហើយនិយាយទៀតថា ‘ដីនោះ ខ្ញុំមិនអាចប្រើឱ្យមានប្រសិទ្ធិភាពល្អទេ’”។

“បាននិយាយថា ទិញដីនោះក្នុងតម្លៃ៥ម៉ឺនដុល្លារ តែលក់ក្នុងតម្លៃ៣ម៉ឺនដុល្លារក៏បានដែរ”

“ចុងចម្លើយបាននិយាយថា ពិគ្រោះជាមួយកូនសិន ហើយនឹងសម្រេច។ កូនរបស់ចុងចម្លើយធ្វើការនៅក្រុមហ៊ុនអចលនទ្រព្យ”

25

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

C) 2-3 សភាពការណ៍ដែលបានដឹងអំពីសារៈសំខាន់

“ពេលចរចារតម្លៃជាមួយចុងចម្លើយ ដើមចោទបាននិយាយថា ‘ដី B នោះ ខ្ញុំមិនអាចប្រើឱ្យមានប្រសិទ្ធិភាពល្អទេ បើពិតជាទិញមែន ថោកបន្តិចក៏លក់ដែរ’ ‘ខ្ញុំមិនអាចប្រើឱ្យមានប្រសិទ្ធិភាពល្អទេ បើទិញភ្លាម ៣ម៉ឺនដុល្លារក៏បានដែរ’ ដើមចោទបានចរចារទិញដោយមានការគិតថា ដីនោះមានការពិបាកនឹងប្រើឱ្យមានប្រសិទ្ធិភាព”។

26

## 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

C) -2-4 ការបង្ហាញឆន្ទៈលុបចោល

"នៅថ្ងៃទី ០ ខែ ០០ ដើមចោទបានបង្ហាញឆន្ទៈលុបចោលនូវកិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ"

27

## រឿងក្ដីស្ដីពីការចុះបញ្ជីលុបនូវការចុះបញ្ជី

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ

28

## 4. ការទទួលស្គាល់ ឬ មិនទទួលស្គាល់

A) កម្មសិទ្ធិរបស់ដើមចោទ (ពេលធ្វើកិច្ចសន្យាលក់ទិញ) ○
B) ការចុះបញ្ជីឈ្មោះចុងចម្លើយ ○
C) -1-1 ការបង្កើតកិច្ចសន្យាលក់ទិញ ○
-2 ការធ្វើលិខិតយថាភូត ○
-3 ការចុះបញ្ជីដោយផ្អែកលើការលក់ទិញ ○
-2-1 ការភាន់ច្រឡំ △មិនដឹង
-2 ចំណុចដែលគិតថាសំខាន់ △មិនដឹង
-3 អង្គហេតុដែលវាយតម្លៃវិជ្ជមាន ×/មួយផ្នែកគឺ ○
-4 ការបង្ហាញឆន្ទៈលុបចោល ○



## 4. ការតវ៉ា

<u>ការលុបចោលដោយការភាន់ច្រឡំ</u>

A) ភាគីម្ខាងទៀតបានដឹងអំពីអង្គហេតុ C-2-3 ដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលវាយតម្លៃអវិជ្ជមាន (មាត្រា 346 កថាខ័ណ្ឌទី2 : អង្គហេតុចំបងដែលជាលក្ខណៈអរូបី)

# 4. ការតវ៉ា

## ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

A) “ពេលពិគ្រោះជាមួយកូនរបស់ខ្លួន ចុងចម្លើយបានទទួលតែចម្លើយថា ‘ទិញជាការល្អ’ ប៉ុណ្ណោះ រីឯស្តីពីផែនការណ៍អភិវឌ្ឍរមនីយដ្ឋាន ឬផែនការណ៍សាងសង់រោងចក្រដុតសម្រាម គឺគ្មាននិយាយអ្វីទាំងអស់’ ។ លើសពីនេះ ចុងចម្លើយក៏មិនទាំងបានដឹងថា កូនរបស់ខ្លួនដឹងអំពីផែនការណ៍ទាំងនេះ ឬមិនដឹងទេ”។

31

## ការទាមទារឱ្យលុបចោលនូវការចុះបញ្ជី

| |
|---|
| កម្មសិទ្ធិរបស់ X (នៅពេលធ្វើកិច្ចសន្យាលក់ទិញ) |
| ការចុះបញ្ជីឈ្មោះY |
| X លក់ទៅឱ្យ Y |
| ធ្វើលិខិតយថាភូត |
| ការចុះបញ្ជីឈ្មោះ Y ដោយផ្អែកលើការលក់ទិញ |
| ការភាន់ច្រឡំ |
| ចំណុចដែលភាគីម្ខាងគិតថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា |
| អង្គហេតុវាយតម្លៃវិជ្ជមានដែលអាចដឹងបាន |
| បង្ហាញឆន្ទៈលុបចោល |

← អង្គហេតុវាយតម្លៃអវិជ្ជមានដែលអាចដឹងបាន

32